ANNA & ASSOCIATES
Law Office


# ព្រឹត្តិបត្រគតិយុត្តខ្លីៗប្រចាំខែ
# ខែមិថុនា ឆ្នាំ ២០២៦
## *ភាគ ៤៦*


## ការដោះស្រាយវិវាទការងារ៖ វិវាទការងាររួម

យោងតាមមាត្រា ៣០២ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៧ «**ច្បាប់ការងារ**» បានចែងថា៖ «*វិវាទរួម គឺជាវិវាទដែលកើតមានឡើងរវាង និយោជកម្នាក់ ឬច្រើននាក់ និងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយវិវាទនេះអាចបណ្តាលឱ្យ សហគ្រាស ប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម ។* » ដែលមានន័យថា វិវាទការងាររួម គឺសំដៅដល់វិវាទដែលកើតឡើងរវាង ថៅកែ ឬថៅហ្វាយនាយកម្នាក់ ឬច្រើននាក់ ជាមួយបុគ្គលិក ឬកម្មករជាក្រុម ដែលទាក់ទងនឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិ ឬវិវាទផ្សេងៗ។

### បច្ចុប្បន្នភាពគតិយុត្ត

*នាថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសលេខ ១១២/២៥ ក.ប/ប្រ.ក.អ.ធ.ក ស្តីពីនីតិវិធី និងលក្ខខណ្ឌនៃការធ្វើការបន្ថែមម៉ោងធ្វើការនៅថ្ងៃឈប់បុណ្យដែលមានប្រាក់ឈ្នួល និងការព្យួរការឈប់សម្រាកប្រចាំសប្តាហ៍ ។*

នាថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥ កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសថ្មីលេខ ០៧៤/២៥ ក.ប/ប្រ.ក.វ.ក ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ដើម្បីកំណត់នូវដំណើរការច្បាស់លាស់ ជំនួសនិតិវិធីចាស់ក្នុងការដោះស្រាយវិវាទការងាររួម ដែលថៅកែ(និយោជក) និងបុគ្គលជាបុគ្គលិក ឬកម្មករ(និយោជិត) ដែលធ្លាប់មានចែងក្នុងប្រកាសលេខ ៣១៧ សកបយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ។

នៅក្នុងអត្ថបទនេះយើងនឹងធ្វើការបកស្រាយនូវ៖ ១. **នីតិវិធីនៅក្នុងការដោះស្រាយវិវាទការងាររួម ២. អនុភាពនៃកំណត់ហេតុផ្សះផ្សា** និង**៣. ភាពខុសគ្នារវាងប្រកាសចាស់ និងប្រកាសថ្មី**។

## ១. នីតិវិធីនៅក្នុងការដោះស្រាយវិវាទការងាររួម

### ក. ការដាក់ពាក្យបណ្តឹង

- **សមត្ថកិច្ចក្នុងការដោះស្រាយវិវាទ៖** នៅពេលមានវិវាទការងាររួមណាមួយកើតឡើងរវាងនិយោជក និងក្រុមកម្មករនិយោកជិត មុននឹងវិវាទនោះឈានដល់ការប្តឹងទៅតុលាការ ឬទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីម្ខាងអាចដាក់ពាក្យបណ្តឹងទៅកាន់នាយកដ្ឋានវិវាទការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។
- **ចំណាត់ការរបស់អធិការការងារពេលមានពាក្យបណ្តឹង៖** នៅពេលទទួលបានពាក្យបណ្តឹង អធិការការងារនឹងពិនិត្យមើលសំណុំរឿង ដើម្បីចាត់វិធានការផ្សះផ្សា ឬចុះធ្វើអធិការកិច្ចការងារ។
- **ចំណាត់ការរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ក្រោយពីបានពិនិត្យមើលសំណុំរឿងរួច អធិការការងារត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង។



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

- **ចំណាត់ការរបស់អ្នកផ្សះផ្សា៖** ការផ្សះផ្សា ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដោយគិតចាប់ពីពេលទទួលបានការចាត់តាំងពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**បញ្ជាក់៖** ការដាក់ពាក្យបណ្តឹងខាងលើអាចធ្វើទៅបាន ក្នុងករណីមានវិវាទការងាររួម លើកលែងតែភាគីទាំងសងខាងមានអនុសញ្ញារួមដែលបានចែងពីនីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយវិវាទរួមនោះ ទើបតម្រូវឱ្យមានការដោះស្រាយតាមនីតិវិធី ដែលមានចែងក្នុងអនុសញ្ញារួមនោះ។ ចំពោះរាល់វិវាទការងាររួមណាដែលប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈវិញ អធិការការងារ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងធ្វើការផ្សះផ្សាភ្លាមៗ ដោយចុះសាកសួរព័ត៌មាន និងធ្វើការផ្សះផ្សាដល់ទីកន្លែងតែម្តង ក្រោយពីទទួលបានដំណឹងអំពីហេតុការណ៍នោះ។

**ខ. ដំណាក់កាលផ្សះផ្សា**

- **ការអញ្ជើញភាគីវិវាទលើកទី១៖** បន្ទាប់ពីការដាក់ពាក្យបណ្តឹងរួចមក អ្នកផ្សះផ្សា នឹងអញ្ជើញភាគីវិវាទទាំងសងខាងមកផ្តល់នូវព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីឱ្យដឹងពីចំណុចវិវាទ និងរកដំណោះស្រាយក្នុងការផ្សះផ្សាវិវាទការងាររួមនេះ។ ការសាកសួរព័ត៌មាន ត្រូវធ្វើឡើងផ្សេងគ្នា ពោលគឺអ្នកផ្សះផ្សានឹងសាកសួរម្តងម្នាក់ ហើយត្រូវធ្វើកំណត់ហេតុ និងមានចុះហត្ថលេខារបស់អ្នកផ្សះផ្សា និងមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីវិវាទ ដែលបានផ្តល់ព័ត៌មាននោះ រួចចម្លងជូនភាគីវិវាទដែលផ្តល់ព័ត៌មានចំនួន ១(មួយ) ច្បាប់។
- **ការអញ្ជើញភាគីវិវាទលើកទី២៖** នៅពេលទទួលបានព័ត៌មានគ្រប់គ្រាន់ហើយ អ្នកផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីវិវាទទាំងអស់មកចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ក្នុងអំឡុងពេលផ្សះផ្សាភាគីវិវាទត្រូវបញ្ឈប់គ្រប់វិធានការវិវាទ។
- **ការពិន័យចំពោះភាគីដែលពុំបានចូលរួម៖** ភាគីវិវាទ ត្រូវចូលរួមប្រជុំរាល់ពេលដែលអ្នកផ្សះផ្សាកោះអញ្ជើញ ក្នុងករណីអវត្តមានដោយគ្មានការបញ្ជាក់មូលហេតុត្រឹមត្រូវ នឹងត្រូវទទួលវិន័យដូចមានចែងក្នុង មាត្រា ៣៦៣ (ត្រូវពិន័យជាប្រាក់ ពីសាមសិបមួយថ្ងៃ ទៅហុកសិបថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ) នៃច្បាប់ស្តីពីការងារ។

**ឧទាហរណ៍៖** កម្មករនិយោជិតម្នាក់ទទួលបានប្រាក់ឈ្នួលក្នុងមួយខែ ៦០០,០០០ រៀល (១៥០ ដុល្លារអាមេរិក) ដោយប្រាក់ឈ្នួលក្នុងមួយថ្ងៃកម្មករទទួលបាន ២០,០០០ រៀល (៥ ដុល្លារអាមេរិក) ក្នុងករណីកម្មករមិនបានចូលរួមប្រជុំដោយគ្មានមូលហេតុត្រឹមត្រូវ នោះកម្មករ នឹងត្រូវទទួលពិន័យជាប្រាក់ចាប់ពី (២០,០០០ រៀល × ៣១ថ្ងៃ = ៦២០,០០០ រៀល ឬ ១៥៥ ដុល្លារអាមេរិក) ដល់ (២០,០០០រៀល × ៦០ថ្ងៃ = ១,២០០,០០០ រៀល ឬ ៣០០ ដុល្លារអាមេរិក)។

- **មោឃៈភាពនៃនីតិវិធីផ្សះផ្សា៖** ក្នុងករណីដើមចោទមិនសហការ ឬមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើឯកសារ ដែលតម្រូវដោយអ្នកផ្សះផ្សានៅក្នុងកិច្ចដំណើរការនៃនីតិវិធីស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ នោះពាក្យបណ្តឹងនឹងត្រូវបានចាត់ទុកជាមោឃៈ។ រាល់ពាក្យបណ្តឹង ដែលត្រូវបានចាត់ទុកជា



*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

មោឃៈដូចក្នុងករណីខាងលើនេះ ប្រសិនបើ ភាគីមានការដាក់ពាក្យបណ្តឹងសារជាថ្មីម្តងទៀតពាក្យបណ្តឹងនោះ មិនអាចយកមកចាត់ការក្នុងនីតិវិធីនៃការផ្សះផ្សានេះបានទៀតទេ។

**គ. ករណីនៅតែមិនសះជា**

- **ការស្នើសុំរួមគ្នាទៅកាន់រដ្ឋមន្ត្រី៖** បន្ទាប់ពីការផ្សះផ្សាវិវាទការងាររួមលើកទីមួយ មិនសះជាក្នុងរយៈពេល ២ (ពីរ) ថ្ងៃធ្វើការ ភាគីវិវាទអាចស្នើសុំជាលាយលក្ខណ៍អក្សររួមគ្នា ទៅកាន់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីផ្សះផ្សាសាឡើងវិញ។ ក្រោយពីទទួលបានលិខិតស្នើសុំរួច រដ្ឋមន្ត្រីអាចចាត់តាំង ឬប្តូរអ្នកផ្សះផ្សាថ្មី ដើម្បីធ្វើការផ្សះផ្សាលើកទីពីរ តាមនីតិវិធីដែលបានកំណត់។
- **ករណីផ្សះផ្សាលើកទី២មិនជោគជ័យ៖** ប្រសិនបើ ការផ្សះផ្សាវិវាទការងារលើកទីពីរនេះមិនសះជាទេ ភាគីវិវាទមិនអាចស្នើសុំឱ្យមានការផ្សះផ្សាជាថ្មីម្តងទៀតបានឡើយ ក្នុងករណីនេះត្រូវអនុវត្តបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬតុលាការមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទការងារ។
- **ការបន្តនីតិវិធីបន្តនៅពេលការផ្សះផ្សាមិនសះជា៖** ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ក្រោយពីវិវាទការងាររួមមិនសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រោយពីទទួលបានដំណឹងក្នុងរយៈពេល ៣ (បី) ថ្ងៃ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមានចំណាត់ការបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបន្តនីតិវិធី។

## ២. អនុភាពនៃកំណត់ហេតុផ្សះផ្សា

រាល់ការប្រជុំផ្សះផ្សា អ្នកផ្សះផ្សា ត្រូវធ្វើកំណត់ហេតុ ដោយបញ្ជាក់ច្បាស់លាស់ថាភាគីវិវាទ(យល់ព្រម ឬមិនយល់ព្រមសះជា) ហើយត្រូវចុះទិដ្ឋាការដោយអ្នកផ្សះផ្សា និងហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីវិវាទ ហើយត្រូវចម្លងជូនភាគីវិវាទ។ ហើយនៅពេលដែលកំណត់ហេតុផ្សះផ្សានេះ បានធ្វើឡើង កំណត់ហេតុផ្សះផ្សានេះមានអនុភាពដូចខាងក្រោម៖

- **ករណីមានសហជីពដែលមានភាពតំណាងបំផុត៖** ការព្រមព្រៀងនេះ មានអានុភាពស្មើនឹងអនុសញ្ញារួម ក្នុងន័យនេះ គឺកិច្ចព្រមព្រៀងនេះអាចយកមកអនុវត្តបាន នៅពេលមានវិវាទការងារលើកក្រោយ ឬអាចប្រើបានចំពោះបុគ្គលផ្សេងទៀតបាន។
- **ករណីមានអ្នកតំណាងនិយោជិតដែលមិនមែនជាសហជីព៖** ករណីអ្នកតំណាងដែលចូលរួមមិនមែនជាសហជីព កិច្ចព្រមព្រៀងនេះ អាចអនុវត្តបានតែចំពោះបុគ្គលដែលត្រូវបានគេតំណាងតែប៉ុណ្ណោះ។

## ៣. ភាពខុសគ្នារវាងប្រកាសចាស់ និងប្រកាសថ្មី

ផ្អែកតាមខ្លឹមសារនៃប្រកាសលេខ ៣១៧ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ (ប្រកាសចាស់) នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងប្រកាសលេខ ០៧៤ ក.ប/ប្រ.វ.ក



*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៥ (ប្រកាសថ្មី) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យើងអាចធ្វើការប្រៀបធៀបនូវចំណុចសំខាន់ៗដូចខាងក្រោម៖

**ក. ការកំណត់រយៈពេល និងវិធានការដោះស្រាយបន្តបន្ទាប់ពីការផ្សះផ្សាមិនសះជា**

- **ប្រកាសចាស់ឆ្នាំ២០០១៖** មិនមានវិធានការចំពោះភាគី ដែលមិនបានចូលរួម មិនមានរយៈពេលច្បាស់លាស់សម្រាប់ចាត់ចែងបន្ត និងមិនបានចែងអំពីស្ថាប័នមានសមត្ថកិច្ចសម្រាប់ដោះស្រាយបន្ត ។
- **ប្រកាសថ្មីឆ្នាំ២០២៥៖** មានការកំណត់ច្បាស់លាស់ដូចជា ការស្នើសុំជាលាយលក្ខណ៍អក្សរ នៅពេលមានករណីមិនសះជា មានរយៈក្នុងការចាត់ចែងបន្ត និងផ្តល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជាអ្នកដោះស្រាយបន្ត។

**ខ. ការធ្វើទំនើបកម្មនៃមធ្យោបាយបញ្ជូនលិខិត**

- **ប្រកាសចាស់ឆ្នាំ២០០១៖** ការបញ្ជូនលិខិត គឺត្រូវធ្វើតាមរយៈប្រៃសណីយ៍ ឬប្រគល់ជូនដោយផ្ទាល់។
- **ប្រកាសថ្មីឆ្នាំ២០២៥៖** ការបញ្ជូនលិខិត គឺត្រូវបានធ្វើតាមមធ្យោបាយទំនើប ដោយអាចធ្វើតាមវិធីផ្សេងដែលអាចទទួលយកបាន (ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ឬបណ្តាញសង្គម) ដើម្បីធានាថាការបញ្ជូនលិខិតមានល្បឿនលឿន សុវត្ថិភាព និងអាចតាមដានបាន។

---

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីម៉ែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋាន៖**

**អាសយដ្ឋានការិយាល័យ**: អាគារ K Plaza លេខ២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



***ការបដិសេធ:*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*